# សិក្ខាសាលាសហព័ន្ធសហគមន៍អ្នកផលិតស្រូវសរីរាង្គ

ដើម្បីរៀបចំសហគមន៍ផលិតស្រូវសរីរាង្គអោយមានលក្ខណៈស្តង់ដា ត្រឹមត្រូវ និងដើម្បីពង្រឹងគណៈកម្មការ ក៏ដូចជាក្រុមអោយមានសមត្ថភាព និងរៀនសូត្រពីបទពិសោធន៍ពីគ្នាទៅវិញទៅមក អង្គការសេដាកបានរៀបចំសិក្ខាសាលាសហព័ន្ធសហគមន៍អ្នកផលិតស្រូវសរីរាង្គថ្នាក់ជាតិ នៅថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១០ នៅការិយាល័យកណ្តាលរបស់ អង្គការសេដាក ក្រុងភ្នំពេញ។

សិក្ខាសាលាសហព័ន្ធសហគមន៍អ្នកផលិតស្រូវសរីរាង្គនេះ ធ្វើឡើងក្នុងគោលបំណងសំខាន់ៗដូចខាងក្រោមៈ

- ពង្រឹងនូវសមត្ថភាពនិងការយល់ដឹងបន្ថែមអំពីការបន្សុតពូជស្រូវ
- ការបង្ហាញរបាយការណ៍ប្រមូលទិញស្រូវក្នុងឆ្នាំ ២០០៩-២០១០
- កាបង្ហាញរបាយការណ៍ពង្រាងទិន្នន័យសំរាប់ឆ្នាំ ២០១០-២០១១
- ផ្សព្វផ្សាយ រៀបចំយុទ្ធសាស្ត្រការងារសំរាប់នៅរដូវខាងមុខ
- រៀបចំយុទ្ធសាស្ត្រប្រមូលទុនភាគហ៊ុនរកស៊ីរួមគ្នារបស់សមាជិកសហព័ន្ធថ្នាក់ជាតិ

កសិករតំណាងសហគមន៍សរុបចំនួន ៥០នាក់មកពីខេត្តចំនួនប្រាំមួយទូទាំងប្រទេសកម្ពុជារួមមានខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង តាកែវ កំពង់ចាម កំពង់ធំ និងព្រៃវែងបានចូលរួមនៅក្នុងសិក្ខាសាលានេះ។

គួររំលឹកថា ដើម្បីអោយកសិករទទួលបាននូវផលចំនេញច្រើនពីផលិតកម្មរបស់ខ្លួន ក៏ដូចជាបាននូវការអនុវត្តកម្មវិធីប្រកបដោយនិរន្តរភាព សេដាកបានផ្តួចផ្តើមគំនិតបង្កើតនូវទីផ្សារ អង្គការសេដាក ដើម្បីភ្ជាប់កសិករមកទីផ្សារ ជាពិសេសផលិតកម្មស្រូវ។ ទីផ្សារអង្គការសេដាក បានទិញស្រូវពីក្រុមតាំងពីឆ្នាំ ២០០៣មកម្លេះ។ ការទិញស្រូវរបស់ទីផ្សារមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលឆ្នាំ ២០០៣ទីផ្សារបានទិញស្រូវចំនួន ១០តោនពីក្រុមផលិតចំនួន ១៨ក្រុម ហើយឆ្នាំ ២០០៩-២០១០នេះ ទីផ្សារបានទិញស្រូវបានចំនួនប្រមាណ ១.៥០០ តោន។

**ស្ថានភាពការលក់ស្រូវសរីរាង្គរបស់សហព័ន្ធអ្នកផលិតស្រូវសរីរាង្គ**

| បរិយាយ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ |
|---|---|---|---|---|---|---|---|
| ក្រុមផលិត | ១៨ | ១១៤ | ២២៨ | ៣៦០ | ៤៣៤ | ៧៧២ | ៣២២ |
| សមាជិកក្រុមផលិត | ២៥៣ | ២០៩៧ | ២០០៤ | ៣០០១ | ៣៦០៤ | ៨០១០ | ២៦៦៨ |
| បរិមាណស្រូវលក់ | 0 | ១០តោន | ១២៥តោន | ៤៨០តោន | ១២០០តោន | ១៣៨០តោន | ១៤៩២តោន |

## ការទទួលផលប្រយោជន៍

សហពន្ធ័សហគមន៍ស្រូវសរីរាង្គពីមួយឆ្នាំទៅមួយឆ្នាំមានការរីកចំរើនគួរឱ្យកត់សំគាល់ ទាំងតំបន់គោលដៅចំនួនក្រុម និងចំនួនសមាជិកព្រមទាំងចំនួនភាគហ៊ុន។ ចំណែកឯសមាជិកសហពន្ធ័សហគមន៍វិញក៏ទទួលបានផលប្រយោជន៍ជាច្រើនដូចជា លក់ស្រូវទទួលបាននូវតំលៃមួយសមរម្យប្រកបដោយជញ្ជីងយុត្តិធមិ ការចំណាយលើ

ការផលិតកម្មមានការថយចុះ បរិស្ថានដីស្រែគ្មានជាតិគីមី ហើយសមាជិកអ្នកផលិតខ្លួនឯងក៏ទទួលបានសុខភាពល្អដោយគ្មានការប៉ះពាល់សារធាតុគីមី។ មិនតែប៉ុណ្ណោះសហគមន៏ក៏មានឱកាស ក្នុងការទទួលបានប្រាក់ចំណេញពីសហគ្រាសសេដាកមួយចំណែក ដើម្បីយកទៅអភិវឌ្ឍន៏មូលដ្ឋានដូចជា ជួសជួលផ្លូវលំ ប្រពន្ធ័បង្ហូរទឹក...។ល។ រីឯអតិថិជនអ្នកបរិភោគវិញ ក៏ទទួលបានផលប្រយោជន៏ផងដែរទាក់ទងទៅនិងសុវត្តិភាពចំណីរអាហារ ដែលធ្វើឱ្យសុខភាពរបស់ពួកគាត់និងមនុស្សជាទីស្រទ្បាញ់មានសុខភាពល្អ។

**ការងារយកចិត្តទុកដាក់បន្ថែម**

នៅក្នុងឆ្នាំ ២០១០នេះសហពន្ធ័សហគមន៏ស្រូវសិរីរាង្គ បានសង្កត់ធ្ងន់ទៅលើ ការបន្សុតពូជដើម្បីធ្វើយ៉ាងណាឱ្យគុណភាពអង្ករកាន់តែមានរស់ជាតិឆ្ងាញ់ និងក្លិនកាន់តែក្រអូបទ្ធេឡើង។

សហពន្ធ័ឈរលើគោលការ : ស្មគ្រចិត្ត ជួយខ្លួនឯង ជួយគ្នាទៅវិញទៅមក រកស៊ីរួមគ្នា គោរពលទ្ធិប្រជាធិបតេយ្យ គិតផលប្រយោជន៏រួម សមភាព សមធមិ...។ល។

